- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ៥៨រូប នៃរដ្ឋបាលខេត្តព្រះសីហនុ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

១- លោក	សិម សុធី	នាយករងទីចាត់ការសាលាខេត្តព្រះសីហនុ
២- លោក	ស៊ាន ដានីន	នាយករងទីចាត់ការសាលាខេត្តព្រះសីហនុ
៣- លោកស្រី	និ អាមិនា	ប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៤- លោក	លឹម វ៉ាន់ដារី	អនុប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៥- លោក	យន ម៉ន	នាយករងរដ្ឋបាលសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
៦- លោក	មាស សារិទ្ធ	នាយករដ្ឋបាលសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
៧- លោក	ច្រឹក រាហ៊ុល	មន្ត្រីសាលាខេត្តព្រះសីហនុ

៨- លោក នន់ រ៉ាថារ័ត្ន មន្ត្រីសាលាខេត្តព្រះសីហនុ

ខ-មេដាយ **ប្រាក់ការងារ**

១- លោក កេទ សុវណ្ណ អនុប្រធានអង្គភាពច្រកចេញចូលតែមួយសាលាខេត្តព្រះសីហនុ
២- លោកស្រី ឈួ ប៉ាវទាង ប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៣- លោក ខឹម សុផល អនុប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៤- លោក លេង វាសនា អនុប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៥- លោក ជា ពិសិដ្ឋនរៈ អភិបាលរងក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
៦- លោកស្រី ផាត់ ម៉ូលិកា អនុប្រធានការិយាល័យសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
៧- លោកស្រី សុខ រាសី អនុប្រធានការិយាល័យច្រកចេញចូលតែមួយសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
៨- លោក ឈួន សុកក្តី អនុប្រធានការិយាល័យសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
៩- លោកស្រី ជាម ជីតា អនុប្រធានការិយាល័យសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
១០- លោក សៃ វិសាល មន្ត្រីសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ
១១- លោក ហេង សុខគុន ប្រធានការិយាល័យសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ
១២- លោក ចាន់ សេង ប្រធានអង្គភាពលទ្ធកម្មសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

គ-មេដាយ **សំរិទ្ធការងារ**

១- លោកស្រី ស៊្រុន ស្រីនាង ប្រធានអង្គភាពច្រកចេញចូលតែមួយសាលាខេត្តព្រះសីហនុ
២- លោក ឡុង ប៊ុនសៀង អនុប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៣- លោក ហួន គុណ អនុប្រធានការិយាល័យសាលាខេត្តព្រះសីហនុ
៤- លោក លឹម គុណអាន មន្ត្រីសាលាខេត្តព្រះសីហនុ
៥- លោក សៅ វឌ្ឍសា មន្ត្រីសាលាខេត្តព្រះសីហនុ
៦- លោក សេត ចិន្តា មន្ត្រីសាលាខេត្តព្រះសីហនុ
៧- លោក នួន សំអាន មន្ត្រីសាលាខេត្តព្រះសីហនុ
៨- លោកស្រី ព្រាប ឌីនីពណ៌ មន្ត្រីសាលាខេត្តព្រះសីហនុ
៩- លោក នៅ ប៊ុនថន មន្ត្រីសាលាខេត្តព្រះសីហនុ
១០- លោក គៀត វង្សច័ន្ទភូមាន មន្ត្រីសាលាខេត្តព្រះសីហនុ
១១- លោក អាន ជាវិទ្ធ មន្ត្រីសាលាខេត្តព្រះសីហនុ
១២- លោកស្រី សន ស្រីនួ មន្ត្រីសាលាខេត្តព្រះសីហនុ
១៣- លោក អែម រ័ត្នម៉ានិល អភិបាលរងក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
១៤- លោក ពិសាល មិថុនា នាយករងរដ្ឋបាលសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
១៥- លោក ជា បុត្តរតនា ប្រធានការិយាល័យសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
១៦- លោក អៀង យ៉ា អនុប្រធានការិយាល័យសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
១៧- លោកស្រី អៀ ឃាងឡេង អនុប្រធានការិយាល័យសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
១៨- លោក លៀម ព្រូ អនុប្រធានការិយាល័យសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
១៩- លោក ផល វង្សឌី អនុប្រធានការិយាល័យសាលាក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
២០- លោក ប៊ុន សៀ ស្មៀនសង្កាត់កោះរ៉ុងសន្លឹម ក្រុងកោះរ៉ុង ខេត្តព្រះសីហនុ
២១- លោក ម៉ម សុចិត្រា មន្ត្រីសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
២២- លោកស្រី ម៉ក់ ចាន់ដាក៉ា មន្ត្រីសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

២៣- លោកស្រី ណំ សូនី មន្ត្រីសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

២៤- លោកស្រី រាម កនិកា មន្ត្រីសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

២៥- លោក ស្មាន សាលេស អនុប្រធានការិយាល័យច្រកចេញចូលតែមួយសាលាក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

២៦- លោក ឈិត អេងលន អនុប្រធានការិយាល័យសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ

២៧- លោកស្រី ជួន សុខុម អនុប្រធានការិយាល័យច្រកចេញចូលតែមួយសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ

២៨- លោក សល់ឡេះ យូសុះ អភិបាលរងស្រុកព្រៃនប់ ខេត្តព្រះសីហនុ

២៩- លោក ប៉ុស វិបុល ប្រធានការិយាល័យសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣០- លោក គង់ សំអាន ប្រធានការិយាល័យសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣១- លោក លឹម ផេង អនុប្រធានការិយាល័យសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣២- លោកស្រី ឌី ស៊ីវហ៊ួន អនុប្រធានការិយាល័យសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣៣- លោកស្រី ឃិន បូរមី អនុប្រធានការិយាល័យច្រកចេញចូលតែមួយសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣៤- លោក ជា ហ៊ុលវឌ្ឍនា មន្ត្រីសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣៥- លោកស្រី ហាយ សុគន្ធា អនុប្រធានការិយាល័យសាលាស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣៦- លោកស្រី រី សោភ័ណ្ឌ ស្មៀនឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣៧- លោក កុល កេសេរ៉ា ប្រធានការិយាល័យច្រកចេញចូលតែមួយសាលាស្រុកកំពង់សីលា ខេត្តព្រះសីហនុ

៣៨- លោក ចិន ផានិត នាយករងរដ្ឋបាលស្រុកកំពង់សីលា ខេត្តព្រះសីហនុ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤

សាយអរដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .-

តែងតាំងនិងផ្តល់ឋានៈលោកស្រី **ហឿក ហ៊ីមុល្លី** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយករង។

មាត្រា២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ ._

ផ្ទេរភារកិច្ចលោកស្រី **ហៀក ហ៊ីម្មុលី** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៣ ពីអភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

មាត្រា២ .—

តែងតាំងលោកស្រី **ម៉ាក សំណាង** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ។

មាត្រា៣ .—

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អាទិត្យ ៤កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈ-អភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .–

តែងតាំងលោក **ស៊ី សួន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរងនៃគណៈអភិបាលខេត្តស្ទឹងត្រែង សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

មាត្រា២ .–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈ-អភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .—

តែងតាំងមន្ត្រីរាជការចំនួន២រូប ជាអភិបាលនៃគណៈអភិបាលស្រុក នៅក្នុងខេត្តស្ទឹងត្រែង សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម :

១- លោក **លី មីណា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ

២- លោក **សុវណ្ណ ពិសេដ្ឋ** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអភិបាលនៃគណៈអភិបាលស្រុកសេសាន។

មាត្រា២ .—

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ [illegible]កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **មាសការងារ** ជូនមន្ត្រីរាជការចំនួន ៥រូប នៃរដ្ឋបាលខេត្តស្ទឹងត្រែងដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ហាក់ វិមាន សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង

២- ឯកឧត្តម ផាន់ ម៉េងឈឿន សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង

៣- ឯកឧត្តម សាត ស៊ិន សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង

៤- ឯកឧត្តម ឈុន កុសល សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង

៥- ឯកឧត្តម ឈួ ស៊ុន សមាជិកក្រុមប្រឹក្សាខេត្តស្ទឹងត្រែង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ១៤កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការចំនួន ៦៤រូប នៃរដ្ឋបាលខេត្តស្ទឹងត្រែង ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក- មេដាយ **មាសការងារ**

១-	លោក	កែវ សំអុល	នាយកទីចាត់ការសាលាខេត្តស្ទឹងត្រែង
២-	លោក	ម៉ៃ ចិត្រា	ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៣-	លោក	មី សុភា	នាយករងទីចាត់ការសាលាខេត្តស្ទឹងត្រែង
៤-	លោក	កាន់ សាវុធ	នាយករងទីចាត់ការសាលាខេត្តស្ទឹងត្រែង
៥-	លោក	លាង រចនា	នាយករងទីចាត់ការសាលាខេត្តស្ទឹងត្រែង
៦-	លោកស្រី	ភឿន សុខា	នាយករងទីចាត់ការសាលាខេត្តស្ទឹងត្រែង

៧- លោកស្រី ចាន់ទ្រី សុភារី ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង

៨- លោក ចាន់ ប៊ុនជុំ ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង

៩- លោកស្រី សាក់ សុខា ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង

១០- លោក ព្រហ្ម សុភក្ត្រា អនុប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង

១១- លោក ស៊ុត សុវណ្ណ ប្រធានក្រុមប្រឹក្សា ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

១២- លោក នួន សូរិយា នាយករដ្ឋបាលសាលាស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

១៣- លោក កែវ ប៊ុនរឿន ប្រធានក្រុមប្រឹក្សា ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

១៤- លោក ពក ច័ន្ទមនោរ៉ា អនុប្រធានការិយាល័យសាលាស្រុកសៀមបូក ខេត្តស្ទឹងត្រែង

១៥- លោក ថៃ អ៊ី អភិបាលរងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

១៦- លោកស្រី ប៊ុនរី សុជា នាយករងរដ្ឋបាលសាលាក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

១៧- លោក ស៊ើម ឌីណា នាយករដ្ឋបាលសាលាស្រុកសេសាន ខេត្តស្ទឹងត្រែង

១៨- លោកស្រី កុំ បុប្ផា នាយករងរដ្ឋបាលសាលាស្រុកសេសាន ខេត្តស្ទឹងត្រែង

១៩- លោកស្រី កុំ មន្ថា ប្រធានការិយាល័យសាលាស្រុកសេសាន ខេត្តស្ទឹងត្រែង

២០- លោក ឌី ចាន់សកា អភិបាលរង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង

ខ- មេដាយ **ប្រាក់ការងារ**

១- លោកស្រី កែវ សារឿន អភិបាលរងនៃគណៈអភិបាល ខេត្តស្ទឹងត្រែង

២- លោក ញ៉ែម សារី អភិបាលរងនៃគណៈអភិបាល ខេត្តស្ទឹងត្រែង

៣- លោក យឹម ផែន អភិបាលរងនៃគណៈអភិបាល ខេត្តស្ទឹងត្រែង

៤- លោក ថោង ស្រាន់ អភិបាលរងនៃគណៈអភិបាល ខេត្តស្ទឹងត្រែង

៥- លោក សែន វ៉ាន់ស៊ីម អភិបាលរងនៃគណៈអភិបាល ខេត្តស្ទឹងត្រែង

៦- លោក ញ៉ែម វណ្ណយុត្តិ នាយករដ្ឋបាលសាលាខេត្តស្ទឹងត្រែង

៧- លោក យឹម ហ៊ុយលីម នាយកទីចាត់ការសាលាខេត្តស្ទឹងត្រែង

៨- លោក សុខ ចាន់សំអឿន អភិបាលរងក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

៩- លោក ជ្រឹម ម៉េងហុង នាយក រដ្ឋបាលសាលាក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

១០- លោក ឡុង គឹមហ៊ាន នាយករង ទីចាត់ការសាលាខេត្តស្ទឹងត្រែង

១១- លោក ជា ពិសិដ្ឋ អនុប្រធានអង្គភាពច្រកចេញចូលតែមួយសាលាខេត្តស្ទឹងត្រែង

១២- លោក សេង ធរី ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង

១៣- លោកស្រី ដួង ជាតាម៉ានិច អនុប្រធានអង្គភាពច្រកចេញចូលតែមួយសាលាខេត្តស្ទឹងត្រែង
១៤- លោកស្រី សូនី បុប្ផា អនុប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
១៥- លោក ហៀង សីហា មន្ត្រីសាលាខេត្តស្ទឹងត្រែង
១៦- លោក ម៉ៃ ចាន់សូរិយា មន្ត្រីសាលាខេត្តស្ទឹងត្រែង
១៧- លោកស្រី ឡា ចិន្តា អភិបាលរងស្រុកសៀមបូក ខេត្តស្ទឹងត្រែង
១៨- លោក ចិត្រ ច័ន្ទករី អនុប្រធានការិយាល័យសាលាស្រុកសៀមបូក ខេត្តស្ទឹងត្រែង
១៩- លោក កៀន ចាក់ន់ ប្រធានការិយាល័យសាលាក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
២០- លោក ឯក ទិត្យមករា អនុប្រធានការិយាល័យសាលាក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
២១- លោក លី ខាំតាន់ ស្មៀនសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
២២- លោក ចេង ស្រ៊ាង សមាជិកក្រុមប្រឹក្សា ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

គ- មេដាយ **សំរឹទ្ធការងារ**

១- លោក ហុក វិសិទ្ធ អនុប្រធានអង្គភាពលទ្ធកម្មសាលាខេត្តស្ទឹងត្រែង
២- លោកស្រី ជា សុខម៉ាឡា ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៣- លោក អៀវ សំអាន ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៤- លោក ថន ថុងហ្វៃ ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៥- លោក សំ គុល ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៦- លោក ឡា ចន្ទ្រា អភិបាលរង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង
៧- លោក គង់ ស៊ីណាក់ អនុប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៨- លោក នូ វណ្ណណូ អនុប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
៩- លោក យួន ឌីណា អនុប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
១០- លោក លី តេងឃាង អភិបាលរង ស្រុកសេសាន ខេត្តស្ទឹងត្រែង
១១- លោក លាង ប៊ុននី អនុប្រធានការិយាល័យសាលាស្រុកសៀមបូក ខេត្តស្ទឹងត្រែង
១២- លោក ខេង សុជាតា ប្រធានការិយាល័យសាលាស្រុកសៀមបូក ខេត្តស្ទឹងត្រែង
១៣- លោក ស៊ុយ សុទ្ធី មន្ត្រីសាលាខេត្តស្ទឹងត្រែង
១៤- លោក ពិន សំណាង សមាជិកក្រុមប្រឹក្សា ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
១៥- លោក ធីក តារារស្មី អនុប្រធានការិយាល័យសាលាស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង
១៦- លោក សាំង បូផាំង មន្ត្រីសាលាស្រុកសេសាន ខេត្តស្ទឹងត្រែង

១៧- លោកស្រី	កៀន ចរិយា	មន្ត្រីសាលាស្រុកសេសាន ខេត្តស្ទឹងត្រែង
១៨- លោក	ពក ប៊ុនចម	សមាជិកក្រុមប្រឹក្សា ស្រុកសៀមបូក ខេត្តស្ទឹងត្រែង
១៩- លោក	ខឹម សីហា	អភិបាលរង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង
២០- លោក	ឡាង ប៊ុនខាំ	សមាជិកក្រុមប្រឹក្សា ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង
២១- លោក	តៃ សាពត	ប្រធានការិយាល័យសាលាខេត្តស្ទឹងត្រែង
២២- លោកស្រី	កៀក រាសី	មន្ត្រីសាលាខេត្តស្ទឹងត្រែង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **មាសការងារ** ជូនមន្ត្រីរាជការ ចំនួន ៦រូប នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

១-លោកស្រី	ង៉ូវ សារ៉ុម	ប្រធានការិយាល័យ
២-លោក	សាំង វុត្ថា	ប្រធានការិយាល័យ
៣-លោក	អោក សំអាន	ប្រធានការិយាល័យ
៤-លោក	ស៊ាន រតនៈ	មន្ត្រីជាប់កិច្ចសន្យា
៥-លោក	សូរ សុជាតិ	មន្ត្រីស្ម័គ្រចិត្ត
៦-លោក	ផន ណាយេលីន	មន្ត្រីស្ម័គ្រចិត្ត

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥ នៃអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា១ .-

តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ដូចខាងក្រោម៖

១-ឯកឧត្តម	**ម៉ុក ប៉ាន់**	តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
២-ឯកឧត្តម	**អូន ម៉ីនហាក់**	តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៣-ឯកឧត្តម	**គួក ហ្វីដេរ៉ូ**	តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
៤-ឯកឧត្តម	**សំ សិទ្ធិសេរី**	តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	សមាជិក
៥-ឯកឧត្តម	**ឆាយ ឃុនឡុខ**	តំណាងក្រសួងទេសចរណ៍	សមាជិក
៦-ឯកឧត្តម	**ទុត អ៊ិនទ័ណារ៉ា**	តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៧-ឯកឧត្តម	**ម៉េង និមល**	តំណាងសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
៨-ឯកឧត្តម	**ម៉ិន នារិន**	នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា	សមាជិក
៩-លោក	**រ័ត្ន សារ៉ា**	តំណាងក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១០-លោក	**ហ្វត ឋិទ្ធ**	តំណាងក្រសួងរ៉ែនិងថាមពល	សមាជិក
១១-លោកស្រី	**យ៉េម កែវកល្យាណ**	តំណាងបុគ្គលិកនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា	សមាជិកាស្វ័យប្រវត្តិ។

មាត្រា២ .-

អនុក្រឹត្យលេខ២៧៦ អនក្រ.តត ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០២៤ ✓

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ....០១....សសរ.......

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្ត អនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញសេចក្តីសម្រេចលេខ៦៤ សសរ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

ប្រការ១ .-

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន ដូចខាងក្រោម៖

១-ឯកឧត្តម **ហេង សួរ**	រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
២-លោកជំទាវ **សុវណ្ណា វណ្ណារតន៍**	រដ្ឋលេខាធិការប្រចាំការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធានអចិន្ត្រៃយ៍
៣-ឯកឧត្តម **តាន់ហ៊ាង ជាវ័ណ្ណា**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	អនុប្រធាន
៤-ឯកឧត្តម **ប៉ាវ ហាម ផាន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៥-ឯកឧត្តម **កែវ វិសិដ្ឋ**	អនុរដ្ឋលេខាធិការក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៦-ឯកឧត្តម **សោម ចំណាន**	រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ	សមាជិក
៧-ឯកឧត្តម **ហ៊ូ ទុឡា**	រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ	សមាជិក
៨-ឯកឧត្តម **លឹម ស៊ុយហុង**	អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ	សមាជិក
៩-ឯកឧត្តម **នួន ឫទ្ធី**	អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ	សមាជិក
១០-ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត**	អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ	សមាជិក
១១-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា**	អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១២-ឯកឧត្តម **ថោង សុគន្ធ**	អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសង្គម ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៣-ឯកឧត្តម **សេង សក្ដា**	អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
១៤-ឯកឧត្តម **ជា ភុកហុង**	អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
១៥-លោក **ស្តួង ហ្វួត**	ប្រធានសភាសម្ព័ន្ធសហជីពជាតិ	សមាជិក
១៦-លោក **ផុល ណាន**	ប្រធានសម្ព័ន្ធសហព័ន្ធសហជីពកម្ពុជា	សមាជិក
១៧-លោក **ប៉ាវ ស៊ីណា**	ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ	សមាជិក
១៨-លោក **អាត់ ធន់**	ប្រធានសហភាពការងារកម្ពុជា	សមាជិក
១៩-ឧកញ៉ា បណ្ឌិត **ណាង សុធី**	អនុប្រធានសហព័ន្ធនិយោជក និង សមាគមពាណិជ្ជកម្មកម្ពុជា	សមាជិក
២០-អ្នកឧកញ៉ា **លី យុនថៃ**	ប្រធានសមាគមស្បែកជើងកម្ពុជា	សមាជិក

២១-លោក **សុខ ឡោ**	អនុប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា	សមាជិក
២២-លោក **ខេន លូ**	អគ្គលេខាធិការសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា	សមាជិក។

ប្រការ២ .-

សេចក្តីសម្រេចលេខ៩២ សសរ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ តំណាងសហជីព តំណាងសមាគមនិយោជក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៦ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មករា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ......០២...សសរ......

សេចក្តីសម្រេច
ស្តីពី
ការបំពេញបន្ថែមសមាសភាព
ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ២១៦ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមសំណើរបស់ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង

សម្រេច

ប្រការ១ .-

ត្រូវបានបំពេញបន្ថែមសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ដូចខាងក្រោម៖

១.ឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ ឆេន**	រដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
២.ឯកឧត្តមនាយឧត្តមសេនីយ៍ **ណឹម សុខខ្លិ**	អគ្គនាយកនៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសនៃក្រសួងការពារជាតិ	សមាជិក
៣.ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុក ឈួច**	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក

៤.ឯកឧត្តមឧត្តមសេនីយ៍ឯក **មាស ស៊ីណា**	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
៥.ឯកឧត្តមឧត្តមសេនីយ៍ឯក **កែវ សុដានី**	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
៦.ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុក សីហា**	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
៧.ឧត្តមសេនីយ៍ឯក **ជា វណ្ណា**	អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃក្រសួងការពារជាតិ	សមាជិក
៨.ឧត្តមសេនីយ៍ឯក **ឡាយ ស៊ា**	អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ	សមាជិក
៩.ឧត្តមសេនីយ៍ឯក **ខាត់ សុផល**	អគ្គនាយករងនៃអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ក្រសួងការពារជាតិ	សមាជិក
១០.ឧត្តមសេនីយ៍ឯក **ណឹម សុវត្ថិ**	អគ្គនាយករងនៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសនៃក្រសួងការពារជាតិ	សមាជិក
១១.ឧត្តមសេនីយ៍ឯក **ច័ន្ទ សុភត្រ្តា**	នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការហ្វឹកហ្វឺនអគ្គបញ្ជាការដ្ឋាន	សមាជិក
១២.ឧត្តមសេនីយ៍ឯក **ម៉ម ឃឿន**	នាយរងសេនាធិការចម្រុះ និងជានាយកវិទ្យាស្ថានទ័ពជើងគោក	សមាជិក
១៣.ឧត្តមសេនីយ៍ឯក **អ៊ុំ វន្នី**	នាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ	សមាជិក
១៤.ឧត្តមសេនីយ៍ឯក **គីម វណ្ណា**	នាយកមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា	សមាជិក
១៥.ឧត្តមសេនីយ៍ឯក **ចាន់ នន់វិទ្យា**	មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងគោក	សមាជិក
១៦.ឧត្តមនាវីឯក **វណ្ណា ម៉ុនលៀខ**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក
១៧.ឧត្តមនាវីឯក **ឆៀ សុខា**	មេបញ្ជាការរងកងទ័ពជើងទឹកនិងជាអគ្គលេខាធិការរងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
១៨.ឧត្តមនាវីឯក **ម៉ាន់ ស៊ីវណ្ណា**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក
១៩.ឧត្តមនាវីឯក **ស្រ៊ុន សារឿន**	មេបញ្ជាការរង និងជាមេបញ្ជាការការពារកោះឆ្នេរកងទ័ពជើងទឹក	សមាជិក
២០.ឧត្តមនាវីឯក **ហ៊ីង ពុធដារ៉ា**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក
២១.ឧត្តមនាវីឯក **ហួរ ហាប់**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក
២២.ឧត្តមនាវីឯក **ឆា គឹមតុល**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក
២៣.ឧត្តមនាវីឯក **ជ័យ លាភី**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក
២៤.ឧត្តមនាវីឯក **សំ សុខា**	មេបញ្ជាការរងកងទ័ពជើងទឹក	សមាជិក

២៥.ឧត្តមសេនីយ៍ឯក **មាស វណ្ណា**	ប្រធានក្រុមការងារស្រាវជ្រាវ យុទ្ធសាស្ត្រយោធា អគ្គបញ្ជាការដ្ឋាន	សមាជិក
២៦.ឧត្តមសេនីយ៍ឯក **សេខ វ៉ាន់ធី**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
២៧.ឧត្តមសេនីយ៍ឯក **សៅ ច័ន្ទតារា**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
២៨.ឧត្តមនាវីឯក **ទៀ ម៉ុនលៀម**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
២៩.ឧត្តមនាវីឯក **គ្រួច គីមថុន**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣០.ឧត្តមសេនីយ៍ឯក **ទូច ពលៈ**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣១.ឧត្តមនាវីឯក **ឃុន បូរិន្ទ**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣២.ឯកឧត្តម **ពុំ សុថា**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣៣.ឧត្តមសេនីយ៍ទោ **ហ៊ី តារា**	អគ្គលេខាធិការរងគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣៤.ឧត្តមនាវីទោ **លី ហួត**	មេបញ្ជាការទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣៥.ឧត្តមនាវីទោ **ឯក សំអាន**	មេបញ្ជាការរងទីបញ្ជាការជួរមុខ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ជាតិសន្តិសុខលម្ហសមុទ្រ	សមាជិក
៣៦.ឧត្តមនាវីទោ **ម៉ី ឌីណា**	មេបញ្ជាការមូលដ្ឋានសមុទ្រ កងទ័ព ជើងទឹក	សមាជិក
៣៧.ឧត្តមសេនីយ៍ទោ **សេខ សំរិត**	អគ្គនាយករងនៃអគ្គនាយកដ្ឋាន ភស្តុភារ ហិរញ្ញវត្ថុ និងជានាយកនៃ នាយកដ្ឋានផ្គត់ផ្គង់ ក្រសួង ការពារជាតិ	សមាជិក
៣៨.ឧត្តមសេនីយ៍ទោ **ឡូន សុខូ**	នាយកនៃនាយកដ្ឋានប្រេងឥន្ធនៈ ក្រសួងការពារជាតិ	សមាជិក
៣៩.ឧត្តមសេនីយ៍ទោ **កុសល សុវណ្ណាវិសាល**	នាយកនៃនាយកដ្ឋានបញ្ជូនសារ ក្រសួងការពារជាតិ	សមាជិក

៤០. ឧត្តមសេនីយ៍ទោបណ្ឌិត **យន្ត ជីក**	នាយកនៃនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេសនៃអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ក្រសួងការពារជាតិ	សមាជិក
៤១.ឧត្តមសេនីយ៍ទោ **អ៊ុក ហឿនពិសី**	នាយកនៃនាយកដ្ឋានអភិវឌ្ឍន៍ ក្រសួងការពារជាតិ	សមាជិក
៤២.ឧត្តមសេនីយ៍ទោ **សាយ សក្តិសុធុទ្ធី**	នាយកនៃវិទ្យាស្ថានប្រវត្តិសាស្ត្រយោធា	សមាជិក
៤៣.ឧត្តមសេនីយ៍ទោ **ស៊ិន សុខា**	នាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការ	សមាជិក
៤៤.ឧត្តមនាវីទោ **ហុង ប៉ុន**	នាយសេនាធិការរងកងទ័ពជើងទឹក	សមាជិក
៤៥.ឧត្តមនាវីទោ **គង់ សំបូរ**	នាយសេនាធិការរងកងទ័ពជើងទឹក	សមាជិក
៤៦.ឧត្តមនាវីទោ **ញិល ស៊ីន**	នាយសេនាធិការរងកងទ័ពជើងទឹក	សមាជិក
៤៧.ឧត្តមសេនីយ៍ទោ **ប៉ែន សុក្រឹត្យវិទ្យា**	នាយលេខាធិការដ្ឋាន សេនាធិការចម្រុះ អគ្គបញ្ជាការ	សមាជិក
៤៨.ឧត្តមសេនីយ៍ទោ **អឿ សំអុល**	មេបញ្ជាការ បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការ	សមាជិក។

ប្រការ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង រដ្ឋបាលខេត្តកោះកុង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មករា ឆ្នាំ២០២៤

តប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៣ សសរ

សេចក្តីសម្រេច
ស្តីពី
ការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១២/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៧ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការផ្ទេរ និងតែងតាំងមុខតំណែងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣៤៦ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ស្តីពីការផ្ទេរនិងតែងតាំងមុខតំណែងរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១២៤/០៧៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ ស្តីពីការតែងតាំងមុខតំណែងអនុរដ្ឋលេខាធិការ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទីនិងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី
- បានឃើញសេចក្តីសម្រេចលេខ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារនិងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរបស់រាជរដ្ឋាភិបាល
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៦២ សសរ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារនិងការបែកចែកភារកិច្ចរបស់ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ៤១ សសរ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបែកចែកភារកិច្ចជូនថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់នៃការងារ

សម្រេច

ប្រការ១ .-

ត្រូវបានបែកចែកភារកិច្ចជូន ឯកឧត្តម **សន ច័ន្ទរិទ្ធី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកបេសកកម្មពិសេស។

ប្រការ២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ .-

ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីកាគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងប្រធានគ្រប់អង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

កន្លែងទទួល :

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព អគ្គនាយកដ្ឋាន និងនាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០១ ផក

ផែនការ

ស្តីពី

យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៩ រយៈពេល១ឆ្នាំ(ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

ផ្អែកតាមលទ្ធផល នៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់កន្លងមក យើងពិនិត្យឃើញថា កងកម្លាំងអនុវត្តច្បាប់ ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានខិតខំប្រឹងប្រែង យ៉ាងសកម្មផុលផុស តស៊ូប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនយ៉ាងក្តៅគគុក ដូចភ្លៀងរលឹម ដោយទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ដូចតទៅ៖

- កម្ពុជាទទួលបានការគាំទ្រ និងកិច្ចសហការពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ជាពិសេសករណីធំៗ និងករណីកែច្នៃផលិតសារធាតុញៀន ត្រូវបានបង្ក្រាប និងកាត់បន្ថយស្ទើរតែគ្មានសកម្មភាពក្នុងឆ្នាំ២០២៣
- ការបន្តស្រាវជ្រាវ បង្ក្រាបបទល្មើសសម្អាតប្រាក់ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដោយបានបង្កក រឹបអូសទ្រព្យសម្បត្តិពីក្រុមឧក្រិដ្ឋជនគ្រឿងញៀនបានយ៉ាងច្រើនសន្ធឹកសន្ធាប់ បានរួមចំណែកធ្វើឱ្យកម្ពុជាចាកចេញពីបញ្ជីប្រផេះនៃ FATF
- លទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ចំនួន៨លើកកន្លងទៅ (២០១៧-២០២៣) កងកម្លាំងអនុវត្តច្បាប់បានបើកប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន**៥៥.៣០៥ករណី** ឃាត់ខ្លួនជនសង្ស័យ **១២០.៣០៧នាក់** ចាប់យកសារធាតុញៀនគ្រប់ប្រភេទទម្ងន់ប្រមាណ**២៧.៦៤១គ.ក្រ** និងសារធាតុគីមីផ្សំប្រមាណ**៥២០.០០៥គ.ក្រ** រួមទាំងមធ្យោបាយ សម្ភារៈនិងវត្ថុតាងជាច្រើនទៀត។ ក្នុងនោះសមត្ថកិច្ចបានស្រាវជ្រាវ បានរកឃើញ និងបានបង្ក្រាប បទល្មើសគ្រឿងញៀនដែលមានអង្គការចាត់តាំងចំនួន**៤៣៥ករណី** ឃាត់ខ្លួនមេក្លោង**១៦៤នាក់** និងខ្សែរយៈបណ្តាញ**៨១១នាក់** ហើយបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់។

ទោះបីជាប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលជាវិជ្ជមានដូចបានពោលខាងលើក្តី ផ្អែកតាមនិន្នាការថ្មីនៃការកែច្នៃផលិត ដឹកជញ្ជូន ជួញដូរសារធាតុញៀនជាសកល និងបញ្ហាថ្មីៗមួយចំនួនទៀត ត្រូវបានកត់សម្គាល់ក្នុងកិច្ចប្រតិបត្តិការបង្ក្រាបដូចជា៖ ការប្រើប្រាស់ល្បិចកលនាំចូលនូវសារធាតុគីមីបម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម បន្លំយកមកកែច្នៃផលិតជាសារធាតុញៀន គួបផ្សំ

នឹងការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ នៅតែជាបញ្ហាប្រឈមពុំរ៉ៃដែលត្រូវយកចិត្តទុកដាក់ ចាត់វិធានការដោះស្រាយឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

ដោយពិនិត្យឃើញថា ហានិភ័យដែលបណ្ដាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀន នៅតែបន្តកើតរាលដាល ទាំងនៅក្នុងតំបន់និងលើពិភពលោក រួមទាំងនៅកម្ពុជាផងនោះ **រាជរដ្ឋាភិបាលកម្ពុជា** សម្រេចបន្តរៀបចំកសាង **ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៩ ឆ្នាំ២០២៤** ដើម្បីការពារកិត្តិយស កិត្យានុភាពជាតិ បញ្ចៀសឱ្យបាននូវភាពវង្វេងគ្រោះដោយសារឧក្រិដ្ឋកម្មគ្រឿងញៀន សំដៅធ្វើឱ្យបរិយាកាស សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមកាន់តែមានភាពល្អប្រសើរឡើងថែមទៀត ក៏ដូចជា ការថែរក្សានូវសុខុមាលភាពសង្គម លើកកម្ពស់ការអភិវឌ្ឍធនធានយុវជន និងបង្កើនភាពកក់ក្ដៅនៅក្នុង សង្គមគ្រួសាររបស់ប្រជាពលរដ្ឋ ដែលមានគោលការណ៍និងវិធានការ ដូចខាងក្រោម៖

I. **គោលការណ៍រួម**

- បន្តចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងបទបញ្ជា លេខ០១បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្ដីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ខុសច្បាប់ ដោយខិតខំចាត់វិធានការបង្ការ ទប់ស្កាត់ និងបញ្ចៀសឱ្យបាន មិនឱ្យប្រទេសកម្ពុជាក្លាយជា គោលដៅនៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន និងមិនឱ្យគ្រឿងញៀនបង្កឥទ្ធិពលញាំញី បំផ្លិចបំផ្លាញ សង្គមជាតិ ជាពិសេសកិច្ចខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចនូវការប្ដេជ្ញាចិត្តថា៖ **កម្ពុជាជាប្រទេសគ្មាន គ្រឿងញៀន និងរក្សាគ្រួសារនីមួយៗ ជាគ្រួសារស្អាតស្អំ គ្មានគ្រឿងញៀន** តាមទស្សនវិស័យ **«ចូលរួមទាំងអស់ គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន»**

- អប់រំបំផុសចលនា លើកទឹកចិត្តឱ្យមានការចូលរួមច្រើនកុះករពីគ្រប់សមាសភាពនៃសង្គម សំដៅ បង្កើតបានជាកម្លាំងសរុប មធ្យោបាយសរុប វិធានការសរុប ជាពិសេសស្រទាប់យុវជនក្នុងការប្រយុទ្ធប្រឆាំង គ្រឿងញៀនខុសច្បាប់ ស្របតាមទិសស្លោក **«៣កុំ ១រាយការណ៍»**។ ទន្ទឹមគ្នានេះ ត្រូវជំរុញចលនាផ្សព្វផ្សាយ គោលនយោបាយ **«ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព»** ឱ្យបានសកម្ម ផុលផុសតាមគ្រប់រូបភាព គ្រប់ទីកន្លែង ចំគោលដៅ និងចំមុខសញ្ញា ជាពិសេសសិស្សានុសិស្ស កម្មករ ពលករ ដើម្បីបានជ្រួតជ្រាប យល់ដឹងអំពី គ្រោះថ្នាក់ដោយសារគ្រឿងញៀន និងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្លើយបដិសេធចំពោះគ្រឿងញៀន និងឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀន

- រៀបចំប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (Hotline) ដើម្បីដាក់ឱ្យដំណើរការក្នុងការទទួលព័ត៌មាន និង ចាត់វិធានការដោះស្រាយ និងអន្តរាគមន៍ នៅពេលមានបណ្ដឹង ព័ត៌មាន ឬសំណូមពរពីមជ្ឈដ្ឋាននានា ពាក់ព័ន្ធបទល្មើសគ្រឿងញៀន

- ជំរុញអនុវត្តវិធានការច្បាប់ និងវិធានការរដ្ឋបាលឱ្យបានម៉ឺងម៉ាត់ និងដូចភ្លៀងរលឹម សំដៅស្រាវជ្រាវ រកឱ្យឃើញបណ្ដាញអង្គការចាត់តាំងនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀន ឧបាយកល សកម្មភាពទំនាក់ទំនង ការដឹកជញ្ជូន កែច្នៃ ផលិត ជួញដូរគ្រឿងញៀន រួមទាំងទីតាំងប្រមូលផ្ដុំការប្រើប្រាស់គ្រឿងញៀន ដើម្បីបើក ប្រតិបត្តិការបង្ក្រាបឱ្យដល់ឫសគល់ប្រកបដោយប្រសិទ្ធភាព

- ពង្រឹង និងជំរុញយន្តការត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានរឹងមាំ និងសកម្ម ក្នុងការទប់ស្កាត់ការលួច បង្វែរសារធាតុគីមីផ្សំ យកទៅធ្វើការកែច្នៃផលិតគ្រឿងញៀនខុសច្បាប់

- ខិតខំប្រមូលផ្តុំលើកកម្ពស់សមត្ថភាព លទ្ធភាពគ្រប់គ្រង ព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម អ្នកញៀនគ្រឿងញៀនឱ្យបានល្អប្រសើរថែមទៀត ដើម្បីទប់ស្កាត់ការរីករាលដាលការប្រើប្រាស់គ្រឿងញៀន និងឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀន សំដៅរួមចំណែកកាត់បន្ថយបទល្មើសផ្សេងៗ ដែលទទួលរងឥទ្ធិពលពីគ្រឿងញៀន

- លើកកម្ពស់សមត្ថភាពបំពេញការងាររបស់មន្ត្រីអនុវត្តច្បាប់ទាំងលើវិស័យជំនាញ និងនីតិវិធី ព្រមទាំងត្រូវបង្កើតឱ្យមានកិច្ចសហការគ្នាល្អជាមួយស្ថាប័នអយ្យការ និងតុលាការ ដើម្បីរិះរកវិធីកសាងសំណុំរឿងរឹងមាំ ដើម្បីធ្វើការផ្តន្ទាទោសដល់ក្រុមឧក្រិដ្ឋជនគ្រឿងញៀនឱ្យបានម៉ឺងម៉ាត់តាមច្បាប់

- ពង្រឹង និងពង្រីកវិសាលភាពសហប្រតិបត្តិការឱ្យបានទូលំទូលាយ ជាមួយបណ្តាប្រទេសជាមិត្ត អង្គការជាតិ អន្តរជាតិ ស្ថាប័នអនុវត្តច្បាប់ បរទេសជាដៃគូ ដើម្បីបង្ការ ទប់ស្កាត់ពីចម្ងាយ និងទទួលព័ត៌មានបម្រើឱ្យការបង្ក្រាប ព្រមទាំងធ្វើការដកបទពិសោធពីគ្នាទៅវិញទៅមក និងការជួយឧបត្ថម្ភ គាំទ្រទាំងស្មារតី និងសម្ភារ

- ខិតខំយកចិត្តទុកដាក់ពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវ បង្ក្រាបបទល្មើសសម្អាតប្រាក់ពាក់ព័ន្ធគ្រឿងញៀនដើម្បីកាត់ផ្តាច់ចរន្តហិរញ្ញវត្ថុផ្គត់ផ្គង់ដល់សកម្មភាពរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀន។

II. **ទិសដៅការងារទូទៅ**

១. ទិសដៅការអប់រំ

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីស្នូលក្នុងការផ្សព្វផ្សាយអប់រំ តាមគ្រប់រូបភាព និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជារដ្ឋបាលរាជធានី ខេត្ត ក្នុងការលើកកម្ពស់ ការយល់ដឹង និងការចូលរួមពីគ្រប់មជ្ឈដ្ឋានដូចជា៖

- សហការជាមួយក្រសួងព័ត៌មាន រៀបចំក្រុមការងារវេទិកាគុម្ពល ដើម្បីធ្វើការអប់រំខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមកម្មវិធីទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងត្រូវកំណត់ឱ្យស្ថានីយទូរទស្សន៍ ស្ថានីយវិទ្យុ និងបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម ត្រូវមានកម្មវិធីផ្សាយអំពីការអប់រំគ្រឿងញៀនជាក់លាក់ឱ្យបានជារៀងរាល់ថ្ងៃ

- ពិគ្រោះយោបល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងនិងពង្រីកកម្មវិធីសិក្សា ព្រមទាំងសកម្មភាពអប់រំប្រឆាំងគ្រឿងញៀនជាប្រចាំ សម្រាប់ឱ្យសិស្សានុសិស្សរៀនសូត្រនៅតាមគ្រប់កម្រិតគ្រប់គ្រឹះស្ថានសិក្សា ស្របតាមកម្មវិធីនៃកម្រិតសិក្សានីមួយៗព្រមទាំងបញ្ចូលក្នុងកម្មវិធីប្រឡងផងដែរ

- ជំរុញឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំកម្មវិធីអប់រំប្រឆាំងគ្រឿងញៀនដល់កម្មករ និងនិយោជិតនៅតាមរោងចក្រ សហគ្រាស សិប្បកម្ម និងការដ្ឋានសំណង់នានា

- ស្នើដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យធ្វើការណែនាំដល់ក្រុមហ៊ុនទូរស័ព្ទផ្ញើសារអប់រំប្រឆាំងគ្រឿងញៀន ដល់អ្នកប្រើប្រាស់ឱ្យបានញឹកញាប់ជាប់ជាប្រចាំ

- សហការជាមួយក្រសួងទេសចរណ៍ ដើម្បីកំណត់ឱ្យម្ចាស់ ឬអ្នកកាន់កាប់គ្រប់គ្រងគោលដៅដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ រួមទាំងកន្លែងកម្សាន្តសប្បាយនានា ដាក់តាំង បិតនូវខ្លឹមសារអប់រំ ឬការហាមចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន

- សហការជាមួយសមាគមអ្នកនិពន្ធ សមាគមសិល្បករខ្មែរ ដើម្បីផលិតសារអប់រំខ្លី និងរៀបចំព្រឹត្តការណ៍ផ្សព្វផ្សាយអប់រំអំពីគ្រឿងញៀនខុសច្បាប់ និងផលប៉ះពាល់ដោយសារគ្រឿងញៀន

ទ្រ

- សំណូមពរដល់ក្រសួងធម្មការ និងសាសនា រៀបចំឱ្យមានកម្មវិធី ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំប្រឆាំងគ្រឿងញៀន តាមរយៈកម្មវិធីសាសនា និងការទេសនារបស់ព្រះសង្ឃជូនពុទ្ធបរិស័ទ

- ណែនាំ និងជំរុញគណៈបញ្ជាការឯកភាពរដ្ឋបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងក្រុមការងារថ្នាក់ជាតិគ្រប់ថ្នាក់ ត្រូវរៀបចំឱ្យមានព្រឹត្តិការណ៍ផ្សព្វផ្សាយអប់រំប្រឆាំងគ្រឿងញៀន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមួយកន្លែងឱ្យបានយ៉ាងតិច២លើកក្នុងមួយខែ តាមរយៈវេទិកាសាធារណៈ វេទិកាផ្សព្វផ្សាយគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ឬវេទិកាផ្សេងៗទៀត។

២. វិធានការរដ្ឋបាល

២.១.គណៈបញ្ជាការឯកភាពរដ្ឋបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន៖

- ត្រូវរៀបចំបញ្ជី និងក្ដាប់ឱ្យបាននូវគោលដៅដែលងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន និងត្រូវកោះអញ្ជើញម្ចាស់ទីតាំង ឬអ្នកកាន់កាប់គ្រប់គ្រងអាជីវកម្មទាំងនោះ មកធ្វើការពន្យល់ណែនាំឱ្យយកចិត្តទុកដាក់ក្នុងការងារគ្រប់គ្រងឱ្យបានហ្មត់ចត់ ព្រមទាំងធ្វើកិច្ចសន្យាសហការបង្ការ ទប់ស្កាត់មិនឱ្យកើតមានបទល្មើសគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន

- ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងចាត់វិធានការម៉ឺងម៉ាត់ ដាច់ខាត ដើម្បីបិទ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្ដោះអាសន្ន ឬជាស្ថាពរចំពោះទីតាំងអាជីវកម្មណាដែលបណ្តែតបណ្តោយឱ្យមានសកម្មភាពជួញដូរ ឬប្រើប្រាស់គ្រឿងញៀន

- ត្រូវមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ សហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ រោងចក្រ សហគ្រាស និងវិស័យឯកជននានា ដើម្បីមានវិធានការ និងមានកិច្ចសហការក្នុងការបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀន ឬអនុវត្តវិធានការរដ្ឋបាល។

២.២.អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ ប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ដោយមិនត្រូវឱ្យមានការលបលាក់ ឬនាំចូលសារធាតុញៀនផ្ដល់ឱ្យពិរុទ្ធជន ឬទណ្ឌិត និង/ឬមានទំនាក់ទំនងពីក្នុងពន្ធនាគារចេញមកខាងក្រៅឬពីមជ្ឈដ្ឋានខាងក្រៅមកក្នុងពន្ធនាគារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ ជាមួយគ្នានេះ ត្រូវពិចារណាលើវិធានការគ្រប់គ្រងជនល្មើសដែលពាក់ព័ន្ធគ្រឿងញៀន ឬសេពគ្រឿងញៀន ដាច់ដោយឡែកពីទណ្ឌិត ឬពិរុទ្ធជនដទៃទៀត។

៣. វិធានការព្យាបាល ស្ដារនីតិសម្បទា និងសមាហរណកម្ម

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្ត និងគាំទ្រ ជានានិរន្តរភាពនៃកិច្ចដំណើរការនៃមជ្ឈមណ្ឌលបណ្ដោះអាសន្នសម្រាប់ព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកងពលតូចថ្មើរជើងលេខ៣១ និងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ កែវផុស

- ក្រសួងសុខាភិបាល ត្រូវខិតខំលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈក្នុងការបន្សាប និងព្យាបាល ព្រមទាំងពង្រីកសេវាបន្សាប ព្យាបាលដោយផ្អែកលើសហគមន៍នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីចូលរួមចំណែកកាត់បន្ថយការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋាន

ជ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹង និងពង្រីកសមត្ថភាពមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្ដារនីតិសម្បទា របស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះ តាមការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ក្នុងយុទ្ធនាការនេះ

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន ដោយត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ អំពីមុខសញ្ញាប្រើប្រាស់ និងងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន។ ទន្ទឹមគ្នានោះ ត្រូវជំរុញនិងលើកទឹកចិត្តអ្នកដែលមិនទាន់ទទួលបានការព្យាបាល ឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រងចំពោះបុគ្គល ដែលបានសមាហរណកម្មចូលក្នុងសហគមន៍ បន្ទាប់ពីចាកចេញពីមណ្ឌលព្យាបាល និងស្ដារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅមូលដ្ឋានរបស់ខ្លួន ជាពិសេសលើកទឹកចិត្តវិស័យឯកជន ដើម្បីចូលរួមក្នុងការគាំទ្រ ឬបង្កើតមជ្ឈមណ្ឌលសម្រាប់អប់រំ បន្សាប ព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណសម្បត្តិលើកទឹកចិត្តដល់មណ្ឌលបណ្ដោះអាសន្នឯកជន ដែលបន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀន។

៤. វិធានការអនុវត្តច្បាប់

៤.១.គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំកម្លាំងអនុវត្តច្បាប់ និងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការម៉ឺងម៉ាត់ក្នុងការស្វែងរកឱ្យឃើញនិងទប់ស្កាត់ការលួចលាក់នាំចូលគ្រឿងញៀនខុសច្បាប់ឆ្លងកាត់ព្រំដែន ចូលមកក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួន ឬឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយទៀត ដោយត្រូវយកចិត្តទុកដាក់៖

- ជំរុញការបើកករណីតស៊ូ ស្រាវជ្រាវ បង្ក្រាបមេខ្លោង និងបណ្ដាញជួញដូរគ្រឿងញៀនឆ្លងដែន បញ្ជូនទៅតុលាការផ្ដន្ទាទោសតាមច្បាប់ និងខិតខំស្រាវជ្រាវករណីសេសសល់ដែលមិនទាន់បានបញ្ចប់

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតពួកជួញដូរគ្រឿងញៀនជាក្រុមតូចៗ ឱ្យបានម៉ឺងម៉ាត់ តឹងរឹងបំផុត និងអនុវត្តវិធានការច្បាប់

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតអ្នកប្រើប្រាស់គ្រឿងញៀន តាមវិធីសហការជាមួយអាណាព្យាបាល សាលារៀន ឬសហគមន៍ ដើម្បីអប់រំ ព្យាបាលនៅតាមសហគមន៍ (ករណីស្រាល) ឬបញ្ជូនទៅមណ្ឌលបន្សាបព្យាបាល និងស្ដារនីតិសម្បទា (ករណីធ្ងន់ធ្ងរ) និងករណីចាំបាច់អនុវត្តវិធានការដាក់ទណ្ឌកម្មក្រោម**៤៨ម៉ោង** ដោយឱ្យធ្វើការងារហត្ថកម្ម ឬអនាម័យតាមទីសាធារណៈ

- តាមដាន គ្រប់គ្រង និងបង្ក្រាបឱ្យបានម៉ឺងម៉ាត់នូវសកម្មភាពកែច្នៃ ផលិតគ្រឿងញៀនសំយោគ ការដាំដុះ ការចម្រាញ់ ការនាំចូលវត្ថុធាតុដើមជាសារធាតុគីមីផ្សំដែលអាចកែច្នៃ ផលិតគ្រឿងញៀនសំយោគ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ធ្វើជាអ្នកសម្របសម្រួល ដើម្បីជំរុញកិច្ចពិគ្រោះ ពិភាក្សារវាងស្ថាប័នអយ្យការ តុលាការ ជាមួយ អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ដើម្បីធ្វើឱ្យកិច្ចសហការ កាន់តែមានដំណើរការរលូន លុបបំបាត់ និទណ្ឌភាព និងរិះរកវិធីកសាងសំណុំរឿងរឹងមាំ ដើម្បីធ្វើការផ្តន្ទាទោសដល់មេខ្លោង និងបណ្តាញជួញដូរ គ្រឿងញៀនឱ្យបានម៉ឺងម៉ាត់ ស្របតាមច្បាប់។

៤.២.ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តជាប់ព្រំដែន ដែលមានការិយាល័យ BLO ត្រូវសហការ ជាមួយមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ រៀបចំកិច្ចប្រជុំ ត្រួតពិនិត្យក្នុងមួយខែម្តង ជាមួយប្រធាន និងមន្ត្រីការិយាល័យ BLO ដើម្បីជំរុញលើកទឹកចិត្តឱ្យមាន កិច្ចសហការរួមគ្នា ក្នុងការផ្តល់ព័ត៌មាន និងផ្លាស់ប្តូរសភាពការណ៍ជាប់ជាប្រចាំ។

៤.៣.គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ត្រូវខិតខំ សហការជាមួយភាគីឡាវ ដើម្បីផ្លាស់ប្តូរព័ត៌មាន និងសហការស៊ើបអង្កេតរកមុខសញ្ញា ឈានទៅបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមព្រំដែន។

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវ បន្តបើកទូលាយកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយប្រទេសជិតខាង ក៏ដូចជាអង្គការអន្តរជាតិសំខាន់ៗ ដើម្បីផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលា និងនិន្នាការប្រែប្រួលនៃបញ្ហាគ្រឿងញៀនតាមដំណាក់កាល នីមួយៗ ក្តាប់បានអំពីខ្សែរយៈទំនាក់ទំនង និងបែបផែនសកម្មភាពរបស់ពួកឧក្រិដ្ឋជន គ្រឿងញៀន ដើម្បី ម្ចាស់ការលើការវិធានការទប់ស្កាត់ពីចម្ងាយ និង/ឬធ្វើការបង្ក្រាបបានទាន់ពេល ក្នុងនោះ យកចិត្តទុកដាក់ ទាំងកិច្ចសហប្រតិបត្តិការថ្នាក់ជំនាញ និងមន្ត្រី BLO ដែលឈរជើងតាមព្រំដែន

- អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវបើកទូលាយចំពោះកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និង/ឬព័ត៌មានតាមករណីនីមួយៗ ជាមួយអង្គការ UNODC INTERPOL ជាមួយស្ថាប័នត្រួតពិនិត្យគ្រឿងញៀន និងស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសនានា ជាពិសេសបណ្តាប្រទេសដែលជាប្រភពនៃការនាំចូលគ្រឿងញៀន ឆ្លងកាត់កម្ពុជា ដើម្បីមានវិធានការក្នុងការបង្ក្រាបអង្គការចាត់តាំង ឬបណ្តាញជួញដូរគ្រឿងញៀនជាអន្តរជាតិ ឱ្យដល់ឫសគល់។

III. **ការចាត់តាំងអនុវត្ត**

១. គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នេះដឹកនាំដោយ៖

- ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន **ជាប្រធាន**

- ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាអនុប្រធាន**។

២. យុទ្ធនាការនេះ ត្រូវមាន**គណៈកម្មការចម្រុះមួយ** ដើម្បីធ្វើជាយន្តការក្នុងការដឹកនាំ បញ្ជា និង ចាត់តាំងអនុវត្ត និងត្រូវមាន**លេខាធិការដ្ឋានមួយ** ជាសេនាធិការ។

៣. ផ្អែកលើផែនការនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវកសាងផែនការសកម្មភាពជាក់ស្តែង តាមវិស័យនិងតាមភូមិសាស្ត្រនីមួយៗ សម្រាប់ចូលរួមអនុវត្តតាមតួនាទីភារកិច្ចរៀងៗខ្លួន ប្រកបដោយ ស្មារតីទទួលខុសត្រូវខ្ពស់។

៤. ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របរៀងរាល់ឆ្នាំដល់បណ្តាអង្គភាព និងបុគ្គលដែលមានស្នាដៃល្អក្នុងការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ព្រមទាំងមានវិធានការអនុវត្តវិន័យ ឬវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះមន្ត្រី ដែលមានជាប់ពាក់ព័ន្ធបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ.សសរ.គសហ

សេចក្តីសម្រេច

ស្តីពី

ការកែសម្រួលក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្ថាប័ន ដើម្បីពិនិត្យ និងវាយតម្លៃលើភាគពួកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលជាយថាហេតុ ដែលកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានកែសម្រួល "ក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្ថាប័ន ដើម្បីពិនិត្យ និងវាយតម្លៃលើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលជាយថាហេតុ ដែលកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន" ហៅកាត់ថា "**ក.ហ.ប.ឯ**" ដែលមានសមាសភាព ដូចខាងក្រោម÷

១-ឯកឧត្តម	**មាស សុខសេនសាន**	រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ)	ប្រធាន
២-ឯកឧត្តម	**សួង ម៉េងគា**	រដ្ឋលេខាធិការ នៃ ក.ស.ហ.វ	អនុប្រធាន
៣-ឯកឧត្តម	**ស៊ឹម ធីរៈ**	អនុរដ្ឋលេខាធិការ នៃ ក.ស.ហ.វ	អនុប្រធាន
៤-ឯកឧត្តម	**ស៊ីន ចាន់សិរីវុត្ថា**	អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រ.ល.អ.ស)	អនុប្រធាន
៥-ឯកឧត្តម	**ឱម ម៉ាក់ឆារិទ្ធ**	អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន (អ.រ.ជ), ក.ស.ហ.វ	អនុប្រធានប្រចាំការ
៦-ឯកឧត្តម	**ម៉ី ថារិន**	អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ)	សមាជិក
៧-ឯកឧត្តម	**ម៉ុក រ៉ាឌី**	អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ)	សមាជិក
៨-ឯកឧត្តម	**កែន រដ្ឋា**	អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, ក្រសួងសាធារណការ និងដឹកជញ្ជូន (ក.ស.ដ)	សមាជិក
៩-ឯកឧត្តម	**ហេង រត្នពិសិដ្ឋ**	អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ, ក.ស.ដ	សមាជិក
១០-លោក	**ហេង សាលពិសិដ្ឋ**	អគ្គនាយករង នៃ អ.រ.ជ, ក.ស.ហ.វ	សមាជិក
១១-ឯកឧត្តមឧត្តមសេនីយ៍ឯក	**ខិន ឆាណាល់**	អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ (ម.ផ)	សមាជិក
១២-ឯកឧត្តម	**សួន តារា**	អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល, ម.ផ	សមាជិក
១៣-ឯកឧត្តម	**មួង រិទ្ធី**	អគ្គនាយករងរដ្ឋបាល និងកិច្ចការទូទៅ, រ.ល.អ.ស	សមាជិក
១៤-លោក	**កុយ សាវរិទ្ធ**	អគ្គនាយករងរដ្ឋបាល និងកិច្ចការទូទៅ, រ.ល.អ.ស	សមាជិក
១៥-លោក	**ជា ណារិន**	អគ្គនាយករង នៃអគ្គនាយកដ្ឋានថាមពល, ក្រសួងរ៉ែ និងថាមពល (ក.រ.ថ)	សមាជិក

១៦-លោក	**ជា សុគ័ន្ធ**	អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប), ក.ស.ហ.វ	សមាជិក
១៧-លោក	**ណុំ ស៊ីនិត**	អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច), ក.ស.ហ.វ	សមាជិក
១៨-លោក	**ហ៊ីង ច័ន្ទបូរ៉ា**	អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អ.ហ.ក), ក.ស.ហ.វ	សមាជិក
១៩-លោក	**សេង តុលា**	អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម នៃ អ.ស.ហ	សមាជិក
២០-លោកស្រី	**គាន់ ឡានីន**	ប្រធាននាយកដ្ឋានប្រគល់ និងត្រួតពិនិត្យគម្រោង នៃ អ.រ.ជ, ក.ស.ហ.វ	សមាជិក
២១-លោក	**យ៉ន សម្បត្តិ**	ប្រធាននាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃ អ.គ.ប, ក.ស.ហ.វ	សមាជិក
២២-លោក	**ពាំង ឆៃរ៉ុល**	ប្រធាននាយកដ្ឋានអភិវឌ្ឍថាមពល នៃ អគ្គនាយកដ្ឋានថាមពល, ក.រ.ថ	សមាជិក
២៣-លោក	**ស្រេង សុខវឌ្ឍ**	ប្រធាននាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង នៃអគ្គនាយកដ្ឋានទឹកស្អាត, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន)	សមាជិក
២៤-លោក	**ស ម៉ិនអ៊ាង**	អនុប្រធាននាយកដ្ឋានប្រគល់ និងត្រួតពិនិត្យគម្រោង នៃ អ.រ.ជ, ក.ស.ហ.វ	សមាជិក
២៥-លោក	**ទួន សុគាផល្លា**	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ, ក.ស.ហ.វ	សមាជិក
២៦-លោក	**ម៉េន លុច**	អនុប្រធាននាយកដ្ឋាន នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម, ក.ស.ហ.វ	សមាជិក
២៧-លោក	**ជា គឹមតុង**	អនុប្រធាននាយកដ្ឋាន នៃ អ.ទ.ច, ក.ស.ហ.វ	សមាជិក
២៨-លោក	**គឹម គុយទេង**	អនុប្រធាននាយកដ្ឋាន នៃ អ.ហ.ក, ក.ស.ហ.វ	សមាជិក
២៩-លោកស្រី	**ខុន បូនីតា**	អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប), ក.ស.ហ.វ	សមាជិក
៣០-លោក	**ស៊ុន ឈុនហៀង**	អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល, ម.ផ	សមាជិក
៣១-លោក	**ជន ឌីណា**	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ	សមាជិក

		នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ, ឱ.វ.ប.ន	
៣២-លោក	**ហ៊ុយ រតនៈ**	អនុប្រធាននាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ, នៃ ក.ប.ទ	សមាជិក
៣៣-លោកស្រី	**កែវ ពេជ្រ**	នាយករងហិរញ្ញកិច្ច-គណនេយ្យ នៃអគ្គិសនីកម្ពុជា (អ.ក)	សមាជិក
៣៤-លោក	**ស៊ុក សទ្ធាពេជ្រ**	នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ	សមាជិក
៣៥-លោកស្រី	**ហួរ ចន្ទ្រមណីរ័ត្ន**	ប្រធានការិយាល័យត្រួតពិនិត្យ និងទិន្នន័យគម្រោង នៃ អ.រ.ជ, ក.ស.ហ.វ	សមាជិក
៣៦-លោក	**សោខ សេរីរដ្ឋ**	ប្រធានការិយាល័យគ្រប់គ្រងហានិភ័យ នៃនាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល នៃ អ.ស.ប, ក.ស.ហ.វ	សមាជិក
៣៧-លោក	**កែវ ខេមរិន្ទ**	ប្រធានការិយាល័យគ្រប់គ្រងគម្រោងឯកជន នៃនាយកដ្ឋានផែនការយុទ្ធសាស្ត្រ និងគម្រោងការ នៃ អ.ក	សមាជិក
៣៨-លោក	**ម៉េត មាសគត្តី**	នាយកទីចាត់ការផែនការ និងវិនិយោគ នៃសាលារាជធានីភ្នំពេញ	សមាជិក
៣៩-លោក	**ម៉ែន ម៉ាណា**	អនុប្រធានការិយាល័យត្រួតពិនិត្យ និងទិន្នន័យគម្រោង នៃ អ.រ.ជ, ក.ស.ហ.វ	សមាជិក
៤០-លោក	**តែ សុខា**	អនុប្រធានលេខាធិការដ្ឋាន នៃ អ.ទ.ច, ក.ស.ហ.វ	សមាជិក
៤១-លោក	**កែវ ពេជ្រ**	ជំនួយការ ឯកឧត្តម សួង ម៉េងគា	សមាជិក

ប្រការ២.–

គ.ហ.ម.គ មានការិយាល័យត្រួតពិនិត្យ និងទិន្នន័យគម្រោង នៃនាយកដ្ឋានប្រគល់ និងត្រួតពិនិត្យគម្រោង នៃ អ.រ.ជ នៃ ក.ស.ហ.វ ជាលេខាធិការដ្ឋានបំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ។

ប្រការ៣.–

គ.ហ.ម.គ មានភារកិច្ច ដូចខាងក្រោម÷

- ចងក្រងព័ត៌មាន និងទិន្នន័យ ពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងទិន្នន័យពាក់ព័ន្ធផ្សេងទៀត សម្រាប់ជាគុណប្រយោជន៍ នៃការវិភាគ និងគ្រប់គ្រងហានិភ័យ
- ពិនិត្យ និងវាយតម្លៃលើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលជាយថាហេតុ ដែលកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

- សិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសនានា ក្នុងគោលបំណងបន្តពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលជាយថាហេតុ ដែលកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៤.-

ក្នុងករណីមានតម្រូវការ, អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវសហការផ្តល់ព័ត៌មានដែលស្ថិតក្រោមសមត្ថកិច្ចរបស់ស្ថាប័ន ឬអង្គភាពផ្ទាល់ មក **ក.ហ.ប.ត** ដើម្បីមានមូលដ្ឋានគ្រប់ជ្រុងជ្រោយក្នុងការវាយតម្លៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលជាយថាហេតុ។

ប្រការ៥.-

អនុប្រធាន និងសមាជិក នៃ **ក.ហ.ប.ត** ត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធាន អាចផ្ទេរសិទ្ធិជូនអនុប្រធាន ឬសមាជិកណាម្នាក់ ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ។

ក.ហ.ប.ត មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងៗទៀតនៃក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមការងារ និងចូលរួមកិច្ចប្រជុំតាមការចាំបាច់។

ប្រការ៦.-

សេចក្តីសម្រេចលេខ ០៣០ សហវ.សសរ.អរជ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង្កើត **"ក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្ថាប័ន ដើម្បីពិនិត្យ និងវាយតម្លៃលើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលជាយថាហេតុដែលកើតចេញពីគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន"** និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៧.-

អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន និងប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ.០០៤.........សហវ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលការចុះបញ្ជីដីធ្លីមានលក្ខណៈ ជាប្រព័ន្ធនិងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបាន ការលើកលែងពន្ធប្រថាប់ត្រាស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ និងការបញ្ជូនសំណុំ ឯកសារដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/០១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០០១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងមុខតំណែងឥស្សរជនជារដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៧ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរនិងការតែងតាំងមុខតំណែងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងមុខតំណែងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៧៥ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងនិងការផ្ដល់ឋានៈជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១០១ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីវិធាននិងនីតិវិធីនៃការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រា
- បានឃើញប្រកាសលេខ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការប្រមូលពន្ធប្រថាប់ត្រា
- យោងតាមការងារចាំបាច់

សម្រេច

ប្រការ១.-

បង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រាស្របតាមបទប្បញ្ញត្តិស្ដីពីពន្ធដារ ព្រមទាំងការបញ្ជូនសំណុំឯកសារ ដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ (ហៅថាក្រុមការងារអន្តរក្រសួង) ដែលមានសមាសភាពដូចខាងក្រោម ៖

១.	ឯកឧត្តម **គិត ច័ន្ទត្រីស្នា**	អនុរដ្ឋលេខាធិការ	សហប្រធាន
២.	ឯកឧត្តម **ភែន សម្បត្តិ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ	សហប្រធាន
៣.	ឯកឧត្តម **ទ្រី សុគី**	អនុរដ្ឋលេខាធិការ	សហអនុប្រធាន
៤.	លោក **ខឹម តុលា**	ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ	សហអនុប្រធាន
៥.	ឯកឧត្តម លោកជំទាវ	អនុរដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលបន្ទុកសម្របសម្រួលការងារតាមរាជធានី ខេត្ត	សមាជិក
៦.	លោក **ហោ សូផាន់ណារ៉ា**	អគ្គនាយករងនៃអគ្គនាយកសុរិយោដីនិងភូមិសាស្ត្រ	សមាជិក
៧.	លោក **សៅ ថ៉ារី**	ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី	សមាជិក
៨.	លោក **ឡូ ម៉ានិត**	ប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី	សមាជិក
៩.	លោក **ស្រុខ ជុំ**	ប្រធាននាយកដ្ឋានបច្ចេកទេស	សមាជិក
១០.	លោកប្រធានសាខាពន្ធដារខេត្ត		សមាជិក
១១.	លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត		សមាជិក
១២.	លោក **ខ៉ែត ឆៃលាង**	អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៣.	លោក **ខ៉ែត លាន**	អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក
១៤.	លោក **តាំង ហៀងប៊ុង**	អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិក

ប្រការ២.-

ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងារដើម្បីជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រាលក្ខណៈជាអំណោយផ្តាច់ក្នុងរង្វង់ញាតិ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ និងការបញ្ជូនសំណុំឯកសារដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ រហូតដល់ដំណាច់ឆ្នាំ២០២៧
- រៀបចំកិច្ចប្រជុំ ពិនិត្យពិភាក្សា និងរកដំណោះស្រាយបញ្ហាគ្នាមៗ ដើម្បីធ្វើឱ្យការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅទូទាំងប្រទេស និងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- រៀបចំកិច្ចប្រជុំ និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់នៃស្ថាប័នទាំងពីរ
- អនុវត្តភារកិច្ចការផ្សេងទៀតដែលរដ្ឋមន្ត្រីក្រសួងទាំងពីរប្រគល់ជូន។

ប្រការ៣.-

ដើម្បីអនុវត្តភារកិច្ចខាងលើ ក្រុមការងារអន្តរក្រសួងត្រូវរៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (Standard Opertation Procedure-SOP) ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រាស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ និងការបញ្ជូនសំណុំឯកសារដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ។

ប្រការ៤.-

ក្នុងអំឡុងពេលអន្តរកាលនៃការរៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ ការអនុវត្តចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រា ត្រូវបានអនុញ្ញាតឱ្យផ្តល់ជូនប្រជាពលរដ្ឋ និងបន្ទាប់មកបញ្ជូនសំណុំឯកសារមករដ្ឋបាលសារពើពន្ធដើម្បីចុះបញ្ជីនិងកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ សំដៅធានាបាននូវការផ្តល់បណ្ណកម្មសិទ្ធិនិងការកត់ត្រាទិន្នន័យឱ្យបានឆាប់រហ័ស។

ប្រការ៥.-

ក្រុមការងារអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយជាសេនាធិការក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដែលមានសមាសភាពដូចខាងក្រោម៖

១. លោក **ហេ សុផាន់ណារ៉ា**	អគ្គនាយករងនៃអគ្គនាយកសុរិយោដីនិងភូមិសាស្ត្រ	សហប្រធាន
២. លោក **ខឹម តុលា**	ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ	សហប្រធាន
៣. លោក **សៅ ថារី**	ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី	អនុប្រធាន
៤. លោក **នូ ម៉ានិត**	ប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី	អនុប្រធាន
៥. លោក **ស្រុខ ជុំ**	ប្រធាននាយកដ្ឋានបច្ចេកទេស	អនុប្រធាន
៦. លោក **សារិន ចន្ទ្ធា**	ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ	សហអនុប្រធានប្រចាំការ
៧.លោក **រស់ សារ៉ាត់**	អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ	សហអនុប្រធានប្រចាំការ
៨. លោក ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត		សមាជិក
៩. លោក ប្រធានសាខាពន្ធដារខេត្ត		សមាជិក
១០. លោក លោកស្រី អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត		សមាជិក
១១. លោក លោកស្រី អនុប្រធានសាខាពន្ធដារខេត្តទទួលបន្ទុកការិយាល័យសេវាអ្នកជាប់ពន្ធ		សមាជិក
១២. លោក លោកស្រី ប្រធាននិងអនុប្រធានការិយាល័យសេវាអ្នកជាប់ពន្ធនៃសាខាពន្ធដារខេត្ត		សមាជិក
១៣. លោក លោកស្រី ប្រធាននិងអនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ		សមាជិក

លេខាធិការដ្ឋាន មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ របស់ក្រុមការងារអន្តរក្រសួងនេះ ដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចស្របតាមនិយាមនីតិវិធីប្រតិបត្តិការងារ របស់ក្រុមការងារអន្តរក្រសួងនេះ
- រៀបចំកិច្ចប្រជុំ ពិនិត្យពិភាក្សា និងរកដំណោះស្រាយបញ្ហាភ្លាមៗ ដើម្បីធ្វើឱ្យការអនុវត្តនិយាមនីតិវិធីប្រតិបត្តិការងារ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- រៀបចំកិច្ចប្រជុំ និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនក្រុមការងារអន្តរក្រសួងស្តីពីសកម្មភាពការងារប្រចាំខែ ដើម្បីពិនិត្យធ្វើការបូកសរុបការងារសម្រេចបាន
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់ក្រុមការងារអន្តរក្រសួង។

ប្រការ៦.-

ខុទ្ទកាល័យ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានពន្ធដារ គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាមីខ្លួនដូចមានក្នុងប្រការ១ និងប្រការ៥ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កន្លែងទទួល :
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រុមការងារផ្ទៃក្នុងរៀបចំគាត់តែងនិយាមនីតិវិធីប្រតិបត្តិការងារ (Standard Operation Procedure - SOP) **របស់ក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនិងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រាស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ និងការបញ្ជូនសំណុំឯកសារដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ**

គោលបំណងនៃការរៀបចំការងារនេះតាមទម្រង់ វិធីសាស្ត្រគ្រប់គ្រងគម្រោង (Project Management Methodologies) គឺដើម្បីជានាបាននូវភាពជាក់លាក់ច្បាស់លាស់អំពី៖

១. សមាសភាពក្រុមការងារគ្រប់គ្រងគម្រោងនេះ

២. អាណត្តិនៃគម្រោង (ចាប់ផ្តើម និងបញ្ចប់គម្រោង)

៣. ផែនការសកម្មភាព និងការទទួលខុសត្រូវក្នុងការអនុវត្តផែនការសកម្មភាពរបស់សមាជិកក្រុមការងារផ្ទៃក្នុងនីមួយៗ។

I. សមាសភាពក្រុមការងារផ្ទៃក្នុងគ្រប់គ្រងគម្រោង

- ប្រធានក្រុមការងារ ៖ ឯកឧត្តមបណ្ឌិត កែន **សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ
- អនុប្រធានក្រុមការងារ ៖ ឯកឧត្តម **លីម** ហ៊ុយជីវ អគ្គនាយករង
- ប្រធានគ្រប់គ្រងគម្រោង ៖ លោក **ខឹម** តុលា ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- អ្នកសម្របសម្រួលគម្រោង ៖ - លោក ង៉ែត ឆៃលាង អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
  - លោក រស់ សារ៉ាក់ អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- ប្រធាន និងសមាជិកក្រុមការងារបច្ចេកទេស។

II. សមាសភាពក្រុមការងារបច្ចេកទេស

១. ក្រុមការងារចេងក្រងអត្ថបទ

- ប្រធានក្រុមទី១ ៖ លោក ង៉ែត ឆៃលាង (DPT)
  - សមាជិក ៖ លោក តាំង ហៀងប៊ុង
- ប្រធានក្រុមទី២ ៖ លោក រស់ សារ៉ាក់ (DPT)
  - សមាជិក ៖ លោក សុវណ្ណ សម្បូណ៌, លោក ជា សុទ្ធា និងកញ្ញា ធន រ៉ាវី
- ប្រធានក្រុមទី៣ ៖ លោក ង៉ែត លាក (DPT)

- សមាជិក ៖ លោក នួន វិជាតិ និងលោក សៀង សាយពិសិដ្ឋ

២. ក្រុមការងារតុបតែងរចនាបថសៀវភៅ

- ប្រធានក្រុម ៖ លោក រស់ សារ៉ាក់ (DPT)
- សមាជិក ៖ លោក ពិសិដ្ឋ វាសនា និងលោក ប៉ែន ពេជ្រដារ៉ូ

៣. ក្រុមការងារកែសម្រួលអក្ខរាវិរុទ្ធ

- ប្រធានក្រុម ៖ លោក អ៊ិន សំបុក (ទីប្រឹក្សា)

៤. ក្រុមការងារបោះពុម្ព

- ប្រធានក្រុម ៖ លោក ស៊ុន លីដឺនី (DFP)

III. អាណត្តិគម្រោង

គម្រោងនេះនឹងត្រូវចាប់ផ្តើមពី **ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣** និងបញ្ចប់ជាស្ថាពរនៅថ្ងៃទី២០ **ខែធ្នូ ឆ្នាំ២០២៣**

IV. ផែនការសកម្មភាព

ល.រ	ផែនការសកម្មភាព	អ្នកទទួលខុសត្រូវ	កាលបរិច្ឆេទ
១	ក្រុមទី១៖ រៀបចំតាក់តែង៖ - ក្របសៀវភៅ - អារម្ភកថា - មាតិកា - សេចក្តីផ្តើម * ការងារទាំងនេះសហការជាមួយជនបង្គោលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ជនសស)	ក្រុមទី១៖ ដឹកនាំដោយ លោក ង៉ែត ឆៃលាង រួមជាមួយ **ជនសស**	- ចាប់ផ្តើមពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ - បញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣
២	ក្រុមទី២៖ រៀបចំតាក់តែង៖ - គោលបំណង គោលការណ៍ តួនាទី និងភារកិច្ច - ក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្ត	ក្រុមទី២៖ ដឹកនាំដោយ លោក រស់ សារ៉ាក់ រួមជាមួយ **ជនសស**	- ចាប់ផ្តើមពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

	* ការងារទាំងនេះសហការជាមួយជនបង្គោលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់		- បញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣
៣	ក្រុមទី៣៖ រៀបចំតាក់តែង៖ - នីតិវិធីប្រតិបត្តិទាំងស្រុង (រាប់បញ្ចូលទាំងការចុះបញ្ជីដីធ្លី និងនីតិវិធីនៃការរៀបចំ ការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងនីតិវិធីចុះបញ្ជី និងកត់ត្រាទិន្នន័យនៃការបញ្ជូនសំណុំឯកសារនៃការចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យ) * ការងារទាំងនេះសហការជាមួយជនបង្គោលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ក្រុមទី៣៖ ដឹកនាំដោយលោក ង៉ែត លាក រួមជាមួយ **ជនសស**	- ចាប់ផ្តើមពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ - បញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣
៤	ពិនិត្យ និងកែសម្រួលអត្ថាធិប្បាយអត្ថបទទាំងអស់របស់ក្រុមទាំង៣ ខាងលើជាបន្តបន្ទាប់	ក្រុមទី៤៖ ដឹកនាំដោយលោក អ៊ិន សំបុក	- ចាប់ផ្តើមពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ - បញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣
៥	- រៀបចំផ្តុំលទ្ធផលក្រុមការងារទាំង៣ខាងលើ ឱ្យទៅជាឯកសារទាំងស្រុងនៃ SOP ឱ្យបាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ ដើម្បីដាក់ប្រជុំពិនិត្យនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ * ការងារទាំងនេះសហការជាមួយជនបង្គោលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ដឹកនាំដោយលោក ង៉ែត ឆៃលាង	- បញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣
៦	- រៀបចំប្រជុំនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់ឯ.ឧ បណ្ឌិត កែន សម្បត្តិ និងឯ.ឧ លឹម ហ៊ុយជីវ អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ * អញ្ជើញជនបង្គោលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចូលរួមប្រជុំ	ដឹកនាំដោយលោក ខឹម តុលា	- ប្រជុំនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣
៧	- រៀបចំ និងជ្រើសរើសពេងពុម្ព និងចរចាតម្លៃបោះពុម្ពជាបណ្តោះអាសន្ន * ការងារទាំងនេះសហការជាមួយជនបង្គោលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបែងចែកចំនួនបោះពុម្ព និងចំណាយ	ដឹកនាំដោយលោក ស៊ុនលី ជីនី រួមជាមួយ **ជនសស**	- ចាប់ផ្តើមពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ - បញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣

៨	- រៀបចំដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេចតាមឋានានុក្រម ដើម្បីអនុម័ត និងអនុវត្តជាផ្លូវការ	ដឹកនាំដោយលោក ខឹម គុលា	- ប្រជុំនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣
៩	- បោះពុម្ពឯកសារ SOP	ដឹកនាំដោយលោក ស៊ុនលី ជីនី រួមជាមួយ ជនសស	- ចាប់ផ្តើមនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ១៣.០២៤.០១៣.ប្រ.ក

ប្រកាស

ស្តីពី

ការបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ

ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១៣-០២៣-៥៧៦ ប្រ.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីរចនាសម្ព័ន្ធនិងមុខងារ-ភារកិច្ចរបស់អគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ
- យោងប្រកាសលេខ ធ៩-០២៣-៥៧៧ ប្រ.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីរចនាសម្ព័ន្ធនិងមុខងារ-ភារកិច្ចរបស់អគ្គនាយកដ្ឋានប្រតិបត្តិការ

សម្រេច

ប្រការ ១.~

បង្កើត "គណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ" របស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះ ហៅថា "គណៈកម្មាធិការ"។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ប្រការ ២.-

គណៈកម្មាធិការនេះ រួមមានសមាសភាពចំនួន ៩រូប ដូចខាងក្រោមៈ

១. លោកជំទាវ ជា សិរី	ទេសាភិបាល	ប្រធាន
២. ឯកឧត្តម ស៊ុំ សន្និសិទ្ធ	ទេសាភិបាលរង	អនុប្រធាន
៣. ឯកឧត្តម វ័ត្ន សុវណ្ណនរៈ	ទេសាភិបាលរង	អនុប្រធាន
៤. ឯកឧត្តម យឹម លាត	ទេសាភិបាលរង	សមាជិក
៥. ឯកឧត្តម គ្រុយ វាសនា	អគ្គលេខាធិការ	សមាជិក
៦. ឯកឧត្តម គីមទី កោមលី	អគ្គនាយកប្រតិបត្តិការ	សមាជិក
៧. ឯកឧត្តម គិត សុវណ្ណារិទ្ធ	អគ្គនាយកត្រួតពិនិត្យ	សមាជិក
៨. លោក ឃូ វុណ្ណី	អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិកអចិន្ត្រៃយ៍ និង
៩. លោក ហេង បូមករា	អគ្គនាយករងត្រួតពិនិត្យទី១	សមាជិក។

ប្រការ ៣.-

គណៈកម្មាធិការមានភារកិច្ចដូចតទៅៈ

- តាមដានការអភិវឌ្ឍក្នុងវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចជារួម សំដៅគាំទ្របេសកកម្មរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ
- កំណត់ វាយតម្លៃ និងតាមដានហានិភ័យដែលអាចគរពូនជាប្រព័ន្ធ និងផ្តល់ជាអនុសាសន៍លើការប្រើប្រាស់ឧបករណ៍គោលនយោបាយមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្នប្រកបដោយភាពសមស្របនិងបុរេសកម្ម សម្រាប់ទប់ស្កាត់ការគំរាមកំហែងដែលអាចកើតមានមកលើស្ថិរភាពហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា និងជួយគ្រប់គ្រង និង/ឬកាត់បន្ថយហានិភ័យជាប្រព័ន្ធ
- ផ្តល់សេចក្តីណែនាំលើការបង្កើតឧបករណ៍ប្រុងប្រយ័ត្ន ជួយតាមដានការអនុវត្ត និងការវាយតម្លៃជាប្រចាំនូវប្រសិទ្ធភាពនៃវិធានការគោលនយោបាយ ដើម្បីសម្រេចគោលដៅដែលបានកំណត់
- សហការជាមួយគណៈកម្មាធិការផ្ទៃក្នុងផ្សេងទៀត ដើម្បីដាក់ចេញគោលនយោបាយឆ្លើយតបសំដៅដោះស្រាយហានិភ័យដែលអាចកើតមានមកលើប្រព័ន្ធហិរញ្ញវត្ថុ
- សហការជាមួយនិយ័តករផ្សេងទៀត ទាំងក្នុងស្រុកនិងអន្តរជាតិ ក្នុងករណីចាំបាច់ ដើម្បីផ្លាស់ប្តូរទិន្នន័យនិងព័ត៌មាន ក្នុងគោលដៅធានាបាននូវស្ថិរភាពនិងភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា
- ធ្វើសេចក្តីសម្រេចលើបញ្ហាដែលស្ថិតក្រោមដែនសមត្ថកិច្ចនៃមុខងារនិងភារកិច្ចគណៈ-កម្មាធិការ និង

- ផ្សព្វផ្សាយអំពីសេចក្ដីសម្រេចដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការ តាមរយៈមធ្យោបាយទំនាក់ទំនង ឬវេទិកាសមស្របនានា ដោយរួមបញ្ចូលទាំងរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ។

ប្រការ ៤.~

គណៈកម្មាធិការត្រូវប្រជុំយ៉ាងហោចណាស់បីខែម្តង។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានឬអនុប្រធានគណៈកម្មាធិការអាចកោះប្រជុំគណៈកម្មាធិការ នៅពេលណាមួយសមស្រប។ ប្រធានគណៈកម្មាធិការអាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញផ្សេងទៀត ចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

ប្រការ ៥.~

គណៈកម្មាធិការមានក្រុមលេខាធិការដ្ឋានមួយដើម្បីជាជំនួយ មកពីនាយកដ្ឋានពាក់ព័ន្ធ ដែលត្រូវបង្កើតឡើងដោយលិខិតបង្គាប់ការ។ ក្រុមលេខាធិការដ្ឋានមានភារកិច្ច ដូចតទៅ៖

- តាមដានការអភិវឌ្ឍក្នុងប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ចជារួម កំណត់ហានិភ័យដែលមានស្រាប់និងដែលអាចនឹងកើតមានមកលើស្ថិរភាពហិរញ្ញវត្ថុ និងធ្វើបទបង្ហាញជាទៀងទាត់លើការវាយតម្លៃគ្រប់ជ្រុងជ្រោយនៃស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ទៅកាន់គណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ
- រៀបចំការវិភាគហានិភ័យជាប្រព័ន្ធ និងស្នើសុំអន្តរាគមន៍និង/ឬការដាក់ចេញគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នទៅកាន់គណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ ដើម្បីពិចារណាដោយសហការជាមួយនាយកដ្ឋានត្រួតពិនិត្យដែលពាក់ព័ន្ធ
- រៀបចំការវាយតម្លៃលម្អិតអំពីស្ថិរភាពនៃវិស័យហិរញ្ញវត្ថុដែលគ្របដណ្តប់លើគ្រឹះស្ថានហិរញ្ញវត្ថុនានា ទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ ហើយចេញផ្សាយជាសាធារណៈនូវការវាយតម្លៃក្នុងទម្រង់ជារបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់
- ធ្វើស្ត្រេសតេស្តជាទៀងទាត់ ដើម្បីវាយតម្លៃភាពធន់នៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ហើយធ្វើបទបង្ហាញលទ្ធផលទៅកាន់គណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេចលើការអនុវត្តសកម្មភាពចាំបាច់ណាមួយដោយនាយកដ្ឋានត្រួតពិនិត្យដែលពាក់ព័ន្ធ និង
- សហការជាមួយនាយកដ្ឋានផ្សេងទៀតនៃធនាគារជាតិនៃកម្ពុជា ក៏ដូចជានិយ័តករនានាដើម្បីផ្លាស់ប្តូរទិន្នន័យនិងព័ត៌មានដែលទាក់ទងនឹងស្ថិរភាពហិរញ្ញវត្ថុ។

ប្រការ ៦.~

ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ លេខ ធ១៣-០២៣-៤២០ ប្រ.ក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកដ្ឋានប្រតិបត្តិការ អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ២ ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២៤

ទេសាភិបាល៖

ជា-សិរី

កន្លែងទទួល ៖

- ដូចប្រការ ២ និងប្រការ ៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ចម្លងជូន ៖

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៣

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៣៧២/១៩ គ.វ.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតសម្ភារសម្រាប់ក្មេងលេងគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ស៊ូភៀរៀ អ៊ិនហ្វ្លេតថឹបល (ខេមបូឌា) ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ូភៀរៀ អ៊ិនហ្វ្លេតថឹបល (ខេមបូឌា)** ឯ.ក **(SUPERIOR INFLATABLES (CAMBODIA) CO., LTD.)** តំណាងដោយលោក **LIU, SHUANGXUE** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **E93955182** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ បង្កើតរោងចក្រ**ផលិតសម្ភារសម្រាប់ក្មេងលេងគ្រប់ប្រភេទ** ដែលមានទីតាំងស្ថិតនៅ**ភូមិព្រៃខ្វាវ ឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ**។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
សម្ភារសម្រាប់ក្មេងលេងគ្រប់ប្រភេទ	៣២៤០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **" រោងចក្រផលិតសម្ភារសម្រាប់ក្មេងលេងគ្រប់ប្រភេទ ស៊ូកៀវៀ អិនហ្គេតថឺបល (ខេមបូឌា) ឯ.ក "**

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ១៦៧ ឧស.កឧ.ប្រក.០៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុតា

<u>**ចម្លងជូន៖**</u>
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកំពង់ស្ពឺ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
- -រដ្ឋបាលស្រុកគងពិសី
- -រដ្ឋបាលឃុំរកាកោះ

  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ....

ថ្ងៃ.................ខែ.........ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០២៣

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៥៥៨/១៥ គ.វ.ក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន គ័ង ស៊ី អ៊ិនដាសស្ទ្រៀល

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **គ័ង ស៊ី អ៊ិនដាសស្ទ្រៀល (KUANG SHYH INDUSTRIAL CO., LTD.)** តំណាងដោយលោក **LIU, MING-SHENG** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ 351266488 ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ បង្កើតរោងចក្រ**ផលិតគ្រឿងបន្សំស្បែកជើង** ដែលមានទីតាំងស្ថិតនៅ **ភូមិត្រពាំងលាន ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។**

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
គ្រឿងបន្លាស់ស្បែកជើង	១៥២០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រផលិតគ្រឿងបន្លាស់ស្បែកជើង គ័ង ស៊ី អ៊ិនដាសស្ទ្រៀល**"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ៤០៤ ឧស.កឧ.ប្រក.០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តតាកែវ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តតាកែវ
-រដ្ឋបាលស្រុកបាទី
-រដ្ឋបាលឃុំចំបក់
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ....

ថ្ងៃ.......................ខែ.......................ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ២០២៣

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៣៦២៨/១៩ គ.វ.ក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតចំណីសត្វ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ៣១៧៥/២២ គ.វ.ក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការបន្ថែមមុខសញ្ញាផលិតកម្ម នៅលើទីតាំងដដែល របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ខេមបូឌាន ណូបិល ថេស្ត ហ៊្វូដ ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **ខេមបូឌាន ណូបិល ថេស្ត ហ៊្វូដ ឯ.ក** (**CAMBODIAN NOBLE TASTE FOOD CO., LTD.**) តំណាងដោយលោក **CHEN, ZHENLU** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EH0263058** ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ បង្កើតរោងចក្រ**ផលិតចំណីសត្វ និងកែច្នៃស្បែកសត្វ** (**Wet Blue Skin**) ដែលមានទីតាំងស្ថិតនៅ**ភូមិព្រែកសង្កែ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។**

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
១- ចំណីសត្វ	**១០៨០**
២- ស្បែកសត្វ (កែច្នៃ, Wet Blue Skin)	**១៥១១**

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **" រោងចក្រផលិតចំណីសត្វ និងកែច្នៃស្បែកសត្វ ខេមប៊ូឌាន ណូបិល ថេស្គ ហ្វីង ឯ.ក "**

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ២៧៩ ឧវបន.កឧ.ប្រក.០៥ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ និងលិខិតលេខ២០៤១ ឧវបន.កឧ.លស ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ស្តីពីការពង្រីកបន្ថែមមុខសញ្ញាផលិតកម្ម របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឋ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ

បច្ចេកវិទ្យា និងនវានុវត្តន៍

រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងបរិស្ថាន

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-រាជកិច្ច

-វិទ្យាស្ថានស្តង់ដារកម្ពុជា

-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

-សាលាខេត្តព្រះសីហនុ

-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ

-រដ្ឋបាលស្រុកព្រៃនប់

-រដ្ឋបាលឃុំទឹកថ្លា

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៤៤៦ រថ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ លេខ០៤៤៦ រថ.អប្រក.ល ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាព សម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ របស់លោកស្រី **សុខ ភារម្យ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា ដានីភារម្យ** ស្ថិតនៅភូមិពពេល ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង របស់លោកស្រី **សុខ ភារម្យ** (**ម្ចាស់ស្ថានីយ**)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ក្បាលដីស្ថានីយគួរមានប្រវែងអប្បបរមា ២៥ ម៉ែត្រ
២. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ
៣. ត្រូវសង់របងជញ្ជាំងបាំងជិតធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកម្ពស់អប្បបរមា ៣ ម៉ែត្រនៅព្រំដីស្ថានីយដែលជាប់នឹងព្រំដីលំនៅដ្ឋាន
៤. មិនត្រូវមានដាក់ទូល្ហាសេក្បែរទូចាក់ប្រេងឥន្ធនៈ

ក្រសួងរ៉ែ និងថាមពល

៥. មិនត្រូវមានដាក់ប្រអប់ភ្លើង (ប្រភពបញ្ឆេះ) ក្បែរពោងឧស្ម័នឥន្ធនៈ
៦. ចម្ងាយពីពោងឧស្ម័នឥន្ធនៈដាក់លើដីទៅរបងព្រំដីស្ថានីយត្រូវមានប្រវែងអប្បបរមា ៧,៥ ម៉ែត្រ ហើយមិនត្រូវស្ថិតនៅក្នុងរោងមានជញ្ជាំងបាំងជិត តែត្រូវនៅទីស្រឡះអាចឱ្យខ្យល់បក់ផាត់បានល្អ និងត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារពីការប៉ះទង្គិចនានា
៧. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ
៨. ត្រូវរៀបចំរបងការពារពីការប៉ះទង្គិចបំពង់ខ្យល់ប្រេងឥន្ធនៈ
៩. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីរបងព្រំដីស្ថានីយ
១០. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅទីតាំងដែលមានរបងរឹងមាំ ឬ ឃ្លុបការពារពីការប៉ះទង្គិច
១១. ទូចាក់ប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីរបងស្ថានីយ
១២. ត្រូវបំពាក់គន្លឹះអាសន្នជាប់ទូចាក់ប្រេងឥន្ធនៈនីមួយៗ
១៣. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
១៤. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១៥. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១៦. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១៧. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៤៤៦.រ៩.អបក.ឈអ..........ចុះថ្ងៃទី...១៣...........ខែកក្កដា.........ឆ្នាំ២០២២...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០.៤៤៦..រ៩.អបក.ឈអ ចុះថ្ងៃទី.....១៣......ខែ....កក្កដា........ឆ្នាំ២០២២...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ឆ្នាំង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ...១៤កើត..ខែ..អាសាឍ..ឆ្នាំខាល..ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.ខែ.កក្កដា..ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ_សែម

<u>កន្លែងទទួល</u>:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ឆ្នាំង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ:.០៤៤.៧៧...រ.ជ:.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ.០៤៤៧.រ.ជ:.អប្រក.លអ.....**ចុះថ្ងៃទី**.....១៣...**ខែ**...កក្កដា..**ឆ្នាំ២០២២**

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ របស់លោក **មី សំណាង**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

សម្រេច

ប្រការ១._

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា ខេទី (Katy)** ស្ថិតនៅភូមិទទា សង្កាត់ក្របីរៀល ក្រុងសៀមរាប ខេត្តសៀមរាប របស់លោក **មី សំណាង (ម្ចាស់ស្ថានីយ)**។

ប្រការ២._

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣._

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤._

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ត្រូវរៀបចំឱ្យមានជញ្ជាំង ឬ របងការពារបំពង់ខ្យល់ប្រេងឥន្ធនៈពីការប៉ះទង្គិចណាមួយ

២. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគាររបស់ស្ថានីយ

៣. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយក្នុងទីធ្លាស្ថានីយ

៤. ត្រូវរៀបចំអាងញែកសំណល់រឹង ប្រេង និងទឹក

៥. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៦. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
៧. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៤៤៧ រ៉ែ.អប្រក.ឋអ.........ចុះថ្ងៃទី.........១៣.........ខែ..កក្កដា.....ឆ្នាំ២០២២.............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៤៤.៧.ឧ៥:អ៊ែរ.៧អ ចុះថ្ងៃទី.......១៣..ខែ.កក្កដា...........ឆ្នាំ២០២២..នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ..១៥..កើត..ខែ...អាសាឍ.ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ...កក្កដា..ឆ្នាំ២០២២
រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ.សែម

__កន្លែងទទួល:__
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -រដ្ឋបាលខេត្តសៀមរាប
- -ដូចប្រការ១៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០៤៤៨.រ៥.អ.សក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០៤៤៨ រ៥.អ.ប្រក.ឧអ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ របស់លោក **អ៊ុន ធី**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

សម្រេច

ប្រការ១._

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា ធី ហុងលី** ស្ថិតនៅភូមិទួលគ្រួស ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប របស់លោក **អ៊ុន ធី** (**ម្ចាស់ស្ថានីយ**)។

ប្រការ២._

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣._

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤._

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
២. ត្រូវរៀបចំឱ្យមានជញ្ជាំង ឬ របងការពារបំពង់ខ្យល់ប្រេងឥន្ធនៈពីការប៉ះទង្គិចណាមួយ
៣. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយក្នុងទីធ្លាស្ថានីយ
៤. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ

៥. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៦. ត្រូវរៀបចំផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ

៧. ត្រូវបិទស្លាកសញ្ញាបម្រាមស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

៨. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ ០៤៤៨ [illegible] ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០[illegible] របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៤៤៥/១៤.ជ.សប.ក-៧៤ ចុះថ្ងៃទី......១៣....ខែ....កក្កដា.......ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ.....១៥កើត.ខែ..អាសាឍ..ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.ខែ..កក្កដា..ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ_សែម

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០៤៤៩ រ៉ែ.អថព.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០៤៤៩ រ៉ែ.អថព.លអ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់លោក **មុត ប៊ូថង**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា អេស្រើឡុត** ស្ថិតនៅភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ របស់លោក **មុត ប៊ូថង** (**ម្ចាស់ស្ថានីយ**)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានការចម្អិនអាហារក្នុងបន្ទប់ស្នាក់នៅ

២. មិនអនុញ្ញាតឱ្យតាំងលក់អីវ៉ាន់ ដោយគ្មានសណ្តាប់ធ្នាប់ក្នុងទីធ្លាស្ថានីយ ប៉ុន្តែម្ចាស់ស្ថានីយអាចដាក់លក់បាននៅទីតាំងដែលមានការរៀបចំបានត្រឹមត្រូវ នៅឆ្ងាយពីបរិវេណស្ថានីយ

៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ

៤. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីរបងព្រំដីស្ថានីយ
៥. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយក្នុងទីធ្លាស្ថានីយ
៦. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៧. ត្រូវរៀបចំឧបករណ៍បង្ការ និងពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់
៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៩. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១០. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១១. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.–

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ..០៤៤៩.១៩.អសប.ក.ចអ.........ចុះថ្ងៃទី.......១៣..........ខែ..កក្កដា.......ឆ្នាំ២០២២..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.–

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៤៤៩.១៩.អសប.ក.ចអ ចុះថ្ងៃទី.......១៣.....ខែ...កក្កដា........ឆ្នាំ២០២២..នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.–

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ស្ពឺ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ..១៥.កើត..ខែ..អាសាឍ.ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៣.ខែ..កក្កដា.ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ_សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី